**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០៣២០ ......សហវ.......

ថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី ១

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសហការជាមួយធនាគារពាណិជ្ជដៃគូ រួមមាន÷ ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ធនាគារ កាណាឌីយ៉ា ក.អ ក្នុងការបង្កើតប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយផ្សារភ្ជាប់នឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) និងដាក់ឱ្យដំណើរការប្រើប្រាស់ក្នុងជំហានទី១ ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ។ ដូច្នេះ ដើម្បីឱ្យប្រព័ន្ធទូទាត់អេឡិចត្រូនិកនេះដំណើរការបានរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ធនាគារពាណិជ្ជដៃគូទាំងពីរ ជ្រាបដូចតទៅ÷

ក. ក្រសួង និងមន្ទីរជំនាញ ដែលនឹងត្រូវអនុវត្តការបង់ចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក ក្នុងជំហានទី១ រួមមាន÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រួមទាំង មន្ទីរជំនាញនៃក្រសួងទាំង០៣ (បី) នៅទូទាំងប្រទេស។

ខ. បេឡាករ នៃធនាគារពាណិជ្ជដៃគូ ត្រូវបញ្ចូលលេខវិក្កយបត្រ ឬ ស្កេន QR កូដ ដែលមាននៅលើវិក្កយបត្រ ដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS នៅពេលមានអតិថិជនធ្វើការបង់ចំណូលមិនមែនសារពើពន្ធនៅតាមបញ្ជរធនាគារពាណិជ្ជដៃគូ ដោយធនាគារនឹងធ្វើប្រតិបត្តិការតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក ជំនួសឱ្យអតិថិជន និងចេញបណ្ណបង់ប្រាក់ជូនអតិថិជន ដើម្បីរក្សាទុកជាឯកសារ។

គ. ការបង់ចំណូលមិនមែនសារពើពន្ធរបស់អតិថិជនតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក អាចប្រព្រឹត្តទៅដោយប្រើប្រាស់កម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ធនាគារពាណិជ្ជដៃគូ ឬ តាមកម្មវិធីទូរសព្ទដៃឆ្លាតវៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (NRMIS App)។

ឃ. ចំណូលដែលទទួល និងប្រមូលបានតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក នឹងត្រូវផ្ទេរដោយស្វ័យប្រវត្តិទៅគណនីដែលបានបើកដូចមានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នាបំពេញបន្ថែម ស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារសម្រាប់ប្រតិបត្តិការចំណូលមិនមែនសារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) អនុវត្តនៅទូទាំងប្រទេស។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមធនាគារពាណិជ្ជដៃគូ ជ្រាប និងផ្តល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងចូលរួមផ្តល់មតិកែលម្អសម្រាប់ការងារអនុវត្តទៅថ្ងៃអនាគត។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**
- ធនាគារជាតិនៃកម្ពុជា
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ឯកសារ កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666